State of California-Health and Human Services Agency
**Department of Health Care Services**
P.O. Box 989009, West Sacramento, CA 95798-9850

XX/XX/XXXX

S12 –

JOHN OR JANE SAMPLE
1234 SAMPLE STREET
ANYTOWN CA 90000

# អត្ថប្រយោជន៍ Medi-Cal របស់អ្នកនឹងផ្លាស់ប្តូរ

មកដល់ [Member Name] ជាទីគោរពរាប់អាន៖

លិខិតនេះគឺស្តីអំពីអត្ថប្រយោជន៍សុខភាពរបស់អ្នក។ មានការផ្លាស់ប្តូរនៅក្នុងការរ៉ាប់រងលើការធានារ៉ាប់រងសុខភាពរបស់អ្នក។ ឥឡូវនេះ អ្នកនឹងទទួលបានការថែទាំសុខភាពរបស់អ្នកតាមរយៈ **គម្រោងធានារ៉ាប់រងសុខភាព Medi-Cal** នេះ៖

| ឈ្មោះ៖ | គម្រោងសុខភាព៖ | គម្រោងថែទាំធ្មេញ៖ | ការបរិច្ឆេទចាប់ផ្តើម៖ |
|---|---|---|---|
| <Insert Bene's Namexxxx> | <Insert MCPxxxxxxxxxxxxxxx> | Medi-Cal Dental | 2/1/2020 |

## តើមានអ្វីកំពុងផ្លាស់ប្តូរ?

ការរ៉ាប់រងលើសុខភាពរបស់អ្នកបានផ្លាស់ប្តូរទៅជា**សេវាកម្ម** Medi-Cal ដែលមានវិសាលភាពពេញលេញ។ ឥឡូវនេះ អ្នកមានអត្ថប្រយោជន៍កាន់តែច្រើន។ អ្នកនឹងទទួលបានការថែទាំតាមរយៈគម្រោងសុខភាពនៃកម្មវិធី Medi-Cal។

ជាមួយនឹងកម្មវិធី Medi-Cal ដែលមានវិសាលភាពពេញលេញ អ្នកអាចបន្តទទួលបានការថែទាំសុខភាពរហូតដល់ទៅមួយខែពីវេជ្ជបណ្ឌិតណាម្នាក់ដែលព្រមទទួលយកសេវាកម្មគិតថ្លៃសម្រាប់សេវាកម្មដែលប្រើប្រាស់នៃកម្មវិធី Medi-Cal Fee-For-Service (Medi-Cal ធម្មតា)។ នៅពេលអ្នកចុះឈ្មោះនៅក្នុងគម្រោងសុខភាពនៃកម្មវិធី Medi-Cal អ្នកនឹងទទួលបានសេវាកម្មចាំបាច់ខាងវេជ្ជសាស្ត្ររបស់អ្នកតាមរយៈគម្រោងសុខភាពនោះ។

## តើអ្វីទៅជាគម្រោងសុខភាពនៃកម្មវិធី Medi-Cal?

គម្រោងសុខភាពនៃកម្មវិធី Medi-Cal ផ្តល់ជូនអ្នកនូវសេវាកម្មដែលចាំបាច់ខាងវេជ្ជសាស្ត្រតាមរយៈ "បណ្តាញ" (ក្រុម) នៃវេជ្ជបណ្ឌិត។ ពួកគេផ្តល់ជូនការថែទាំសុខភាពបឋម និងបង្ការជាមុន។ នៅពេលលោកអ្នកចូលរួមក្នុងគម្រោងសុខភាពនៃកម្មវិធី Medi-Cal គម្រោងនេះនឹង៖

- ជួយគ្រប់គ្រងការថែទាំរបស់អ្នក
- ជួយអ្នកស្វែងរកវេជ្ជបណ្ឌិត និងអ្នកឯកទេស
- មានបណ្តាញទូរស័ព្ទប្រឹក្សាយោបល់គិលានុបដ្ឋាកយិកា 24 ម៉ោង
- មានសេវាកម្មសមាជិក ដើម្បីជួយអ្នក



MU_0004130_CAM1_1019

- ជួយលោកអ្នកនៅក្នុងមធ្យោបាយធ្វើដំណើរទៅកាន់ការជួបពិគ្រោះវេជ្ជសាស្ត្រ
- ជួយអ្នកឱ្យទទួលបានសេវាកម្មនានា ដែលអ្នកអាចនឹងត្រូវការដែលគម្រោងនេះមិនរ៉ាប់រង

## តើខ្ញុំទទួលបានសេវាកម្មថែទាំធ្មេញបានយ៉ាងដូចម្តេច?

អ្នកនឹងទទួលបានសេវាកម្មថែទាំធ្មេញពីកម្មវិធី Medi-Cal ថែទាំធ្មេញ។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មថែទាំធ្មេញ សូមអានទំព័រ "សំណួរដែលសួរជាញឹកញាប់ (FAQ)"ដែលមានមកជាមួយលិខិតនេះ។ អ្នកនឹងត្រូវការទៅជួបពេទ្យធ្មេញដែលព្រមទទួលយកកម្មវិធី Medi-Cal ថែទាំធ្មេញ។ ដើម្បីស្វែងរកពេទ្យធ្មេញដែលនៅជិតអ្នក សូមហៅទូរស័ព្ទទៅសេវាកម្មអតិថិជននៃកម្មវិធី Medi-Cal ថែទាំធ្មេញ តាមលេខ **1-800-322-6384** (TTY៖ 1-800-735-2922)។

ទំព័រសំណួរដែលសួរជាញឹកញាប់ដែលមកជាមួយលិខិតនេះមានអ្វីច្រើនថែមទៀតស្តីអំពីសេវាកម្មផ្សេងទៀតដែលអាចមានតាមរយៈកម្មវិធី Medi-Cal។ ពួកវារួមមានសេវាកម្មសុខភាពផ្លូវចិត្ត សេវាព្យាបាលគ្រឿងស្រវឹង និងគ្រឿងញៀន ការថែទាំគំហើញ (ភ្នែក) និងសេវាកម្មដែលត្រូវការចាំបាច់ជាលក្ខណៈវេជ្ជសាស្ត្រផ្សេងទៀត។

## តើខ្ញុំអាចទាក់ទងគម្រោងសុខភាព Medi-Cal របស់ខ្ញុំដោយរបៀបណា?

ដើម្បីទាក់ទង៖ <**Insert COHS Plan Name**>

សូមហៅទូរស័ព្ទទៅសេវាកម្មសមាជិកតាមលេខ៖ <Member Services number and TTY here>

ឬចូលមើលពួកវានៅលើបណ្តាញនៅអាសយដ្ឋាន៖ <insert web address>

នៅពេលអ្នកចូលរួមក្នុងគម្រោងសុខភាពនៃកម្មវិធី Medi-Cal ដែលត្រូវបានរាយឈ្មោះខាងលើ ពួកគេនឹងផ្ញើកញ្ចប់ស្វាគមន៍ជូនអ្នក។ អ្នកអាចជ្រើសរើសវេជ្ជបណ្ឌិតនៃគម្រោងសុខភាពនៃកម្មវិធី Medi-Cal នៅថ្ងៃ ឬក្រោយពីកាលបរិច្ឆេទចាប់ផ្តើមបាន។ សូមហៅទូរស័ព្ទទៅលេខទូរស័ព្ទសេវាកម្មសមាជិក ដើម្បីជ្រើសរើសវេជ្ជបណ្ឌិតរបស់អ្នក និងស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍ និងសេវាកម្ម។

ប្រសិនបើអ្នកត្រូវការជំនួយបន្ថែម សូមហៅទូរស័ព្ទទៅកាន់អ្នកសើបអង្កេតបណ្តឹងនៃក្រសួងសេវាកម្មថែទាំសុខភាពតាមលេខ Department of Health Care Services Ombudsman 1-888-452-8609 ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹកដល់ម៉ោង 5 ល្ងាច។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។

## ចុះប្រសិនបើខ្ញុំមានសំណួរច្រើនទៀត?

### សេវាកម្មវិបត្តិនៃការប្រើសារធាតុញៀន

សម្រាប់ជំនួយក្នុងការផ្តល់ប្រឹក្សាផ្នែកសង្គ្រោះបន្ទាន់ សេវាកម្មបន្សាបគ្រឿងញៀន និងការព្យាបាលនៅផ្ទះ ឬការព្យាបាលបែបពិគ្រោះជំងឺក្រៅរយៈពេលវែង សូមទាក់ទងកម្មវិធីនៅមូលដ្ឋានរបស់អ្នកដែលមានរាយឈ្មោះនៅលើគេហទំព័រ បញ្ជីរាយឈ្មោះ និងព័ត៌មានទំនាក់ទំនងប្រចាំខោនធីនៃកម្មវិធីគ្រឿងស្រវឹង និងគ្រឿងញៀនផ្សេងទៀត (Alcohol and Other Drugs Program County Directory) នៅអាសយដ្ឋាន៖
**www.dhcs.ca.gov/individuals/Pages/SUD_County_Access_Lines.aspx**

### សេវាកម្មសុខភាពផ្លូវចិត្ត

ចំពោះសំណួរអំពីអ្វីដែលមិនមែនជាវិបត្តិ សេវាកម្ម ឬព័ត៌មានទូទៅ សូមទាក់ទងក្រសួងសុខភាពផ្លូវចិត្តនៅមូលដ្ឋានរបស់អ្នកដែលមានរាយឈ្មោះនៅលើគេហទំព័រ បញ្ជីទំនាក់ទំនងនៃគម្រោងធានារ៉ាប់រងសុខភាពផ្លូវចិត្តប្រចាំខោនធី (County Mental Health Plan Contact List) នៅអាសយដ្ឋាន៖
**www.dhcs.ca.gov/individuals/Pages/MHPContactList.aspx**

បន្ទាប់ពីអ្នកត្រូវបានចុះឈ្មោះក្នុងគម្រោងសុខភាពនៃកម្មវិធី Medi-Cal ដែលត្រូវបានរាយឈ្មោះខាងលើនោះ អ្នកក៏អាចហៅទូរស័ព្ទទៅលេខទូរស័ព្ទរបស់សេវាកម្មសមាជិកនៃគម្រោងរបស់អ្នកសម្រាប់ជំនួយដល់សេវាកម្មសុខភាពផ្លូវចិត្តបានផងដែរ។

**សេវាកម្មអតិថិជននៃកម្មវិធី Medi-Cal ថែទាំធ្មេញ**
សម្រាប់ជំនួយក្នុងការស្វែងរកអ្នកផ្តល់សេវាកម្មថែទាំធ្មេញនៃកម្មវិធី Medi-Cal ព័ត៌មានអំពីការណាត់ជួបពិនិត្យសុខភាព ឬសំណួរទូទៅអំពីកម្មវិធី Medi-Cal ថែទាំធ្មេញ៖

សូមហៅទូរស័ព្ទទៅកាន់៖ **1-800-322-6384** (TTY៖ 1-800-735-2922) ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹកដល់ 5 ល្ងាចឬទៅកាន់៖ **www.denti-cal.ca.gov/Beneficiaries/Denti-Cal**